ឈ្មោះពេញរបស់សិស្ស
លេខរដ្ឋបាលរបស់សិស្ស
បន្ទប់រៀនរបស់សិស្ស

ឯកសាររបស់មាតាបិតា

# Killester College

## កម្មវិធី Apple MacBook Pro ឆ្នាំ 2012 សម្រាប់ថ្នាក់ទី 07/08

## កិច្ចសន្យាជួលប្រើ Apple MacBook Pro សម្រាប់មាតាឬបិតា និង សិស្ស

### កិច្ចសន្យាជួលប្រើ Apple MacBook Pro សម្រាប់មាតាឬបិតានិងសិស្សនេះ ត្រូវបានធ្វើឡើងរវាង Killester College, សិស្ស, និងមាតាឬបិតា ឬ អាណាព្យាបាលរបស់សិស្ស ហើយបញ្ជាក់នូវការព្រមព្រៀងនៃភាគីទាំងនេះ ដូចតទៅ៖

Killester College ផ្តល់ឲ្យសិស្សថ្នាក់ទី 07/08 នីមួយៗនូវ Apple MacBook Pro មួយ ដើម្បីប្រើនៅពេលសិក្សានៅសាលារៀននេះ។

**សិស្សនីមួយៗនឹងទទួលវត្ថុដូចតទៅ៖**

- Apple MacBook Pro (ឆ្លាក់អក្សរ មានលេខកូដ និងមានស្លាក) នៅក្នុងប្រអប់ដើមនៃ MacBook Pro
- គ្រឿងបរិក្ខារបន្ថែម៖ Charger (ប្រដាប់សាកថ្ម), adaptor (ប្រដាប់សម្រួលភ្លើង), ស្បោងដាក់ និង External Hard Disk Drive

**កម្មសិទ្ធិ**

Killester College នឹងនៅតែជាម្ចាស់កម្មសិទ្ធិនៃ Apple MacBook Pro និងគ្រឿងបរិក្ខារបន្ថែម រយៈពេល 3 ឆ្នាំ។ នៅចុងបញ្ចប់នៃពេលបីឆ្នាំ នេះ បើមាតាបិតាមានបំណងបង់ប្រាក់ $80 ទៅឲ្យ Killester College នោះមាតាបិតានឹងជាម្ចាស់កម្មសិទ្ធិនៃ Apple MacBook Pro និងគ្រឿងបរិក្ខារបន្ថែមនេះ។ (កម្មសិទ្ធិនេះមិនរាប់បញ្ចូល software និងអាជ្ញាប័ណ្ណទេ) ។ សិស្សពុំមានកម្មសិទ្ធិអាជ្ញាប័ណ្ណនៃ software ដែលដាក់បញ្ចូលនៅក្នុងកុំព្យូទ័រ ដែលរួមបញ្ចូលជាមួយ Apple MacBook Pro ឬអាជ្ញាប័ណ្ណនៃ software ដទៃទៀតដែលសាលារៀនអាចដាក់បញ្ចូលនៅគ្រាម្តងម្កាល ទៅក្នុង Apple MacBook Pro ដែលប្រើដោយសិស្សឡើយ។

**ដោយចុះហត្ថលេខា លោកអ្នកបង្ហាញថា លោកអ្នកបានអាននិងយល់ចំណុចដូចតទៅ៖**

**សិស្ស**

1. ខ្ញុំបានអាន និងចុះហត្ថលេខាលើកិច្ចព្រមព្រៀង ICT/អ៊ីនធើណេត របស់ Killester College
2. ខ្ញុំនឹងយក Apple MacBook Pro ទៅសាលារៀនរៀងរាល់ថ្ងៃ ដោយសាកបញ្ចូលថ្ម និងរៀបចំជាស្រេចសម្រាប់ការសិក្សា
3. ខ្ញុំនឹងថែទាំ Apple MacBook Pro របស់ខ្ញុំ ហើយនៅពេលធ្វើដំណើរពីថ្នាក់រៀនមួយទៅកាន់ថ្នាក់រៀនមួយទៀត ខ្ញុំនឹងយកវាទៅជាមួយដោយដាក់នៅក្នុងស្បោងដាក់ Apple MacBook Pro របស់ខ្ញុំ
4. បើខ្ញុំមិនប្រើ Apple MacBook Pro ក្នុងថ្នាក់រៀនទេ ខ្ញុំនឹងចាក់សោទុកវានៅក្នុងទូ Locker របស់ខ្ញុំ
5. ខ្ញុំនឹងមិនឲ្យនរណាមួយទៀតប្រើ Apple MacBook Pro របស់ខ្ញុំ ក្រៅអំពីមាបិតាខ្ញុំឡើយ
6. ខ្ញុំ**<u>នឹងមិន</u>**
   a. ដាក់ឬញ៉ាំភេសជ្ជៈ នៅក្បែរ Apple MacBook Pro ឡើយ
   b. ប្រើដៃធ្ងន់ជាមួយនឹង Apple MacBook Pro ឡើយ
   c. ទុក Apple MacBook Pro របស់ខ្ញុំ នៅក្នុងបន្ទប់ផ្លាស់សម្លៀកបំពាក់, ថ្នាក់រៀន, ក្រៅថ្នាក់រៀន, ឬកន្លែងឯទៀត ដែលគេអាចលួចវាបានឡើយ
   d. យក Apple MacBook Pro ចេញពីស្បោងស្ពាយទៅសាលារៀនរបស់ខ្ញុំ នៅក្នុងពេលធ្វើដំណើរតាមយានជំនិះសាធារណៈ ឬនៅតាមទីកន្លែងសាធារណៈឡើយ
   e. គូសសរសេរលើស្បោងដាក់ MacBook Pro របស់ខ្ញុំឡើយ
7. ខ្ញុំអាចទុកឯកសារទាំងឡាយនៅក្នុង Apple MacBook Pro របស់ខ្ញុំ, ហើយខ្ញុំទទួលខុសត្រូវចំពោះការចម្លងទុកឯកសារ (ដោយប្រើ External Hard Disk Drive ដែលផ្តល់ឲ្យ)។ នៅក្នុងព្រឹត្តិការណ៍នៃការបាត់បង់ឯកសារ ឬបើ Hard Disk Drive ត្រូវការចម្លងឡើងវិញនូវរូបភាព, Killester College នឹងចម្លងឡើងវិញនូវរូបភាព Apple MacBook Pro ឲ្យដល់ក្រុម **software ស្តង់ដារ**

ឈ្មោះពេញរបស់សិស្ស ឯកសាររបស់មាតាបិតា
លេខរដ្ឋបាលរបស់សិស្ស
បន្ទប់រៀនរបស់សិស្ស

8. ខ្ញុំនឹងប្រាប់មាតាបិតានិងគ្រូបង្រៀនខ្ញុំឲ្យបានរហ័សតាមលទ្ធភាព ក្រោយពីកើតមានហេតុការណ៍ណាមួយដូចតទៅនេះ៖
   a. ចោរលួច
   b. ការបាត់បង់
   c. ការខូចខាត

Apple MacBook Pro និងគ្រឿងបរិក្ខារបន្ថែមរបស់ខ្ញុំ

9. Killester College អាចសុំយក Apple MacBook Pro និងគ្រឿងបរិក្ខារបន្ថែម នៅគ្រប់ពេល និងនៅពេលដែលខ្ញុំធ្វើវិស្សមកាលក្នុងអំឡុងឆមាសសិក្សា
10. ខ្ញុំយល់ថា មានការបង់ប្រាក់បន្ថែមចំនួន $350 សម្រាប់បញ្ហា / ការបាត់បង់ / ការខូចខាតដោយចេតនា ដែលគ្មានការធានារ៉ាប់រង ហើយយល់ព្រមបង់ប្រាក់នេះ
11. ខ្ញុំយល់ថា ខ្ញុំនឹងត្រូវបង់ប្រាក់ទៅឲ្យ Killester College ចំពោះការផ្តល់បន្ថែមជាជំនួសនូវ adaptor, ខ្សែភ្លើង, ស្បោងដាក់ និង External Hard Disk Drive ដោយសារតែចោរលួច ការបាត់បង់ ឬការខូចខាត
12. Killester College នឹងប្រមូលយក Apple MacBook Pro និងគ្រឿងបរិក្ខារបន្ថែម នៅពេលបញ្ចប់ឆ្នាំសិក្សានីមួយៗ សម្រាប់គោលបំណងថែទាំ (នេះជាតម្រូវការធានារ៉ាប់រង)

ឈ្មោះសិស្ស (អក្សរធំ) ______________________________

ហត្ថលេខា ______________________________________ ថ្ងៃទី ___________

**មាតាឬបិតា**

1. ខ្ញុំបានអាន និងចុះហត្ថលេខាលើកិច្ចព្រមព្រៀង ICT/អ៊ីនធើរណិត របស់ Killester College
2. ខ្ញុំនឹងធ្វើឲ្យប្រាកដថា កូនស្រីខ្ញុំសាកបញ្ចូលថ្ម រៀងរាល់យប់
3. ខ្ញុំនឹងធ្វើឲ្យប្រាកដថា កូនស្រីខ្ញុំយក Apple MacBook Pro ទៅសាលារៀន រៀងរាល់ថ្ងៃ
4. ខ្ញុំនឹងពិភាក្សានូវការប្រើប្រាស់យ៉ាងសមរម្យនូវអ៊ីនធើរណិត ហើយមើលខុសត្រូវលើការប្រើអ៊ីនធើរណិតរបស់កូនស្រីខ្ញុំ
5. ខ្ញុំនឹងសម្រេចលើ និងអនុវត្តការមើលខុសត្រូវយ៉ាងសមរម្យ ចំពោះការប្រើ Apple MacBook Pro នៅក្រៅពេលម៉ោងសាលារៀន
6. ខ្ញុំនឹងផ្ទេរចម្លង និងដាក់បញ្ចូលកម្មវិធីកុំព្យូទ័រដែលស្របច្បាប់តែប៉ុណ្ណោះ ដែលយកចេញពីអ៊ីនធើរណិត ឬប្រភពផ្សេងទៀត
7. ខ្ញុំនឹងមិនខិតខំជួសជុល Apple MacBook Pro ឡើយ
8. ខ្ញុំនឹងរាយការណ៍ប្រាប់សមាជិកនៃក្រុមបុគ្គលិក IT អំពីបញ្ហាឬការខូចខាតណាមួយនៃ Apple MacBook Pro និងគ្រឿងបរិក្ខារបន្ថែម
9. ខ្ញុំយល់ថា Killester College អាចសុំយកវិញនូវ Apple MacBook Pro និងគ្រឿងបរិក្ខារបន្ថែម នៅគ្រប់ពេលទាំងអស់
10. ខ្ញុំទទួលដឹងឮថា ក្រៅអំពីមាតាបិតារបស់កូនស្រីខ្ញុំ កូនស្រីខ្ញុំនឹងជាជនតែម្នាក់គត់ដែលប្រើ Apple MacBook Pro
11. មុនពេលដែលកូនស្រីខ្ញុំទទួលយក Apple MacBook Pro
    a. ខ្ញុំយល់ព្រមបង់ប្រាក់ចំនួន $400.00 ក្នុងមួយឆ្នាំ ជាថ្លៃជួលនិងថ្លៃធានារ៉ាប់រងសម្រាប់ Apple MacBook Pro
    b. ខ្ញុំយល់ថា មានការបង់ប្រាក់បន្ថែមចំនួន $350 សម្រាប់បញ្ហា / ការបាត់បង់ / ការខូចខាតដោយចេតនា ដែលគ្មានការធានារ៉ាប់រង ហើយយល់ព្រមបង់ប្រាក់នេះ
    c. ខ្ញុំយល់ថា ខ្ញុំនឹងត្រូវបង់ប្រាក់ទៅឲ្យ Killester College ចំពោះការផ្តល់បន្ថែមជាជំនួសនូវ adaptor, ខ្សែភ្លើង, ស្បោងដាក់ និង External Hard Disk Drive ដោយសារតែចោរលួច ការបាត់បង់ ឬការខូចខាត

ឈ្មោះមាតាឬបិតា (អក្សរធំ) _____________________________________________

ហត្ថលេខា ______________________________________ ថ្ងៃទី ___________

**ព័ត៌មានលំអិតនៃ Apple MacBook Pro**

លេខស៊េរី ____IT will merge Serial No.______________________________

**លេខទូរស័ព្ទដៃរបស់មាតាឬបិតា / អាណាព្យាបាល** __________________________

**លេខទូរស័ព្ទដៃរបស់សិស្ស** ___________________________________